# សេចក្តីប្រកាសព័ត៌មាន

កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា សហការជាមួយ អង្គការ Good Return ប្រទេសអូស្ត្រាលី បានដាក់រៀបចំកម្មវិធីដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅអប់រំផ្នែកហិរញ្ញវត្ថុ "**តោះ! និយាយពីលុយ**" ដែលចងក្រងឡើងសម្រាប់ផ្តល់នូវការអប់រំផ្នែកហិរញ្ញវត្ថុដល់កុមារនៅកម្ពុជាដែលមានអាយុចាប់ពី ៨ ដល់ ១២ឆ្នាំ ។

កម្មវិធីនេះត្រូវបានប្រព្រឹត្តិទៅនៅសាលាបឋមសិក្សាភ្នំដូនពេញ ក្រោមអធិបតីភាព **លោកជំទាវ នាវ ច័ន្ទថាណា** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ដោយមានការចូលរួមពី**លោកបណ្ឌិត ម៉ុក សារ៉ុម** អគ្គនាយករងអប់រំ និងជាតំណាងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងមានការចូលរួមពីតំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស សរុបប្រមាណ ៥០០ នាក់ ។

ការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅអប់រំផ្នែកហិរញ្ញវត្ថុនេះ គឺជាជំហានសំខាន់ដំបូង ក្នុងកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជា ជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ជ្រាបការអប់រំផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាទូទៅរបស់ក្រសួង ។

ថ្លែងក្នុងកម្មវិធីនេះ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា មានប្រសាសន៍ថា "ការអប់រំផ្នែកហិរញ្ញវត្ថុ មានសារៈសំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិ ព្រោះការយល់ច្បាស់ពីផលិតផលហិរញ្ញវត្ថុ ការជ្រើសរើស និងការប្រើប្រាស់ផលិតផល ទាំងនោះបានត្រឹមត្រូវ អាចការពារអតិថិជនឱ្យផុតពីការកេងបន្លំ និងបំណុលវ័ន្តក ។ លោកជំទាវ ទេសាភិបាលរង ក៏បានថ្លែងអំណរគុណចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមាន ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដែលបានឧបត្ថម្ភគាំទ្រដំណើរការរៀបចំកម្មវិធីនេះ និងជាពិសេសចំពោះ ក្រសួងអប់រំ យុវជន និងកីឡា ដែលបានអនុញ្ញាតផ្តល់ទីតាំងឲ្យធនាគារជាតិនៃកម្ពុជារៀបចំកម្មវិធីនៅថ្ងៃនេះ ។

ក្នុងខែមីនា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជា សហការជាមួយអង្គការ Good Return បានចាប់ផ្តើមយុទ្ធនាការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដែលមានឈ្មោះថា "តោះ! និយាយពីលុយ" ។ យុទ្ធនាការនេះមានគោលបំណងផ្តល់ការអប់រំផ្នែកហិរញ្ញវត្ថុ តាមរយៈការជំរុញនិងលើកទឹកចិត្តយុវជនឲ្យពិភាក្សាពីសារៈសំខាន់នៃការគ្រប់គ្រងប្រាក់ នៅក្នុងគ្រួសារ និងស្វែងរកព័ត៌មានបន្ថែមសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវក្នុង ការទទួលយកសេវាហិរញ្ញវត្ថុ ។

ក្នុងរយៈពេល ៣ខែ ដំបូង យុទ្ធនាការនេះបានផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋ កម្ពុជាប្រមាណ ១,៥ លាននាក់ តាមរយៈខ្សែវីដេអូអប់រំខ្លីៗនៅលើទូរទស្សន៍និងបណ្តាញ ទំនាក់ទំនងសង្គម ការផ្សាយតាមវិទ្យុ ការផ្ញើសារតាមទូរស័ព្ទ វគ្គអប់រំផ្សព្វផ្សាយនៅតាម សាលារៀន និងរោងចក្រ ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនោះ ប្រជាពលរដ្ឋប្រមាណ ២៦.៨០០ នាក់ បានពិភាក្សាពីខ្លឹមសារនៃយុទ្ធនាការនេះនៅក្នុងចំណោមគ្រួសារនិងមិត្ត ភក្តិរបស់គាត់ ។

លោក Shane Nichols នាយកប្រតិបត្តិអង្គការ Good Return មានប្រសាសន៍ថា "យើងពិតជារំភើបចំពោះជោគជ័យនៃយុទ្ធនាការនេះ ដោយតាមរយៈការផលិតសៀវភៅ អប់រំផ្នែកហិរញ្ញវត្ថុផ្អែកលើសាច់រឿងនៃខ្សែវីដេអូខ្លីទាំង៦ ។ គោលបំណងគឺដើម្បីឲ្យសារ អប់រំនៃយុទ្ធនាការនេះអាចទៅដល់អ្នកប្រើប្រាស់ និងផ្តល់នូវការអប់រំផ្នែកហិរញ្ញវត្ថុ ប្រកបដោយភាពច្នៃប្រឌិតក្នុងការជំរុញការអភិវឌ្ឍសមត្ថភាពមនុស្សវ័យក្មេង" ។

រឿងទាំង៦នេះមានភ្ជាប់ដោយសំណួរ និងចម្លើយ ដែលអាចប្រើប្រាស់សម្រាប់ការ សិក្សាដោយខ្លួនឯង និងលើកទឹកចិត្តដល់យុវជននិងគ្រួសាររបស់គេ ក្នុងការ តថ្លៃ ជ្រើស រើស និងប្រើប្រាស់ផលិតផលហិរញ្ញវត្ថុ ប្រកបដោយការទទួលខុសត្រូវនិងការទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់និងអ្នកផ្តល់សេវាហិរញ្ញវត្ថុ ។

ការអភិវឌ្ឍនៃយុទ្ធនាការ "តោះ! និយាយពីលុយ" ទទួលបានការគាំទ្រពីអង្គការ World Edcuation Cambodia, អង្គការ English Family Foundation, គម្រោង Development Innovations ក្រោមមូលនិធិជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងក្រុមហ៊ុនទូរស័ព្ទ SMART ។ ការផលិតនិងបោះពុម្ពសៀវភៅអប់រំផ្នែក

ហិរញ្ញវត្ថុទទួលបានការឧបត្ថម្ភពីក្រុមហ៊ុន VISA ធនាគារពិភពលោក សាជីវម្មអន្តរជាតិ (IFC) គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងដៃគូឧបត្ថម្ភផ្សេងៗទៀត ។

សម្រាប់ព័ត៌មានបន្ថែមនៃយុទ្ធនាការ" តោះ! និយាយពីលុយ" សូមចូលទៅកាន់ ៖

**Website:** www.talkmoney.info
**Facebook**: www.facebook.com/talkmoneyinfo